**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ១០
ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០១
**<u>សាលដីកា</u>**
លេខ:៨៦
ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក .............. ជាចៅក្រម
៤-លោក ........... ជាចៅក្រមរបាយការណ៍
៥-លោក ............ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-លោក ..............

**<u>តំណាងមហាអយ្យការ</u>**
-ឯកឧត្តម ................. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខលេខ ៦៦(ក) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៨០០ ចុះថ្ងៃទី០៩ ខែធ្នូឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ បសរ ភេទប្រុសអាយុ ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែទីលំនៅភូមិឃ្លាំងប្រាក់ ឃុំប្លេវ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ ឪពួកឈ្មោះ ដួង កន(រ) ម្តាយឈ្មោះ ឌុក អោក (រ) ប្រពន្ធឈ្មោះ អរ។

បានផ្ទេរសិទ្ធិឱ្យឈ្មោះ អរជាប្រពន្ធ

មានមេធាវីលោក ........

និងចុងបណ្តឹងសាទុក្ខឈ្មោះ ឈុន ឈៃ ភេទប្រុសអាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីលំនៅភូមិផ្សារឆ្នាំង ឃុំផ្សារឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។ ឪពួកឈ្មោះ ឈុន គី(ស) ម្តាយឈ្មោះ ឈុន ហុក(រ) ប្រពន្ធឈ្មោះ ម៉ែ ស៊ីវអៀង ។

មានមេធាវី លោក ........

**<u>កម្មវត្ថុបណ្តឹង</u>** ទាមទារដីស្រែ និងដីបាសាំងទឹកទុកជាសម្បត្តិអង្គភាព .

បានឃើញបណ្តឹងសាទុក្ខលេខ៣៧៥ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ របស់លោកបសរ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៦៦(ក) ចុះថ្ងៃទី០១ខែសីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១០ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២០-០៧-៩៨របស់ដើមចោទថាដីបាសាំងទឹក និងដីស្រែគឺជាកម្មសិទ្ធិរបស់បន្ទាយទាហានតាំងពីឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ននេះប៉ុន្តែឈ្មោះបសរ បានរំលោភ បំពានយកជាកម្មសិទ្ធិទៅវិញ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ៣១៨/៩៨ ចុះថ្ងៃទី១៥ ខែកញ្ញាឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំងដែលសម្រេច :

១- ឱ្យចុងចម្លើយឈ្មោះបសរ ធ្វើស្រែវស្សានៅលើផ្ទៃដីទំហំ៦០អា ដែលមានទីតាំង នៅខាងលិចជាប់បន្ទាយចាន់ សារិ ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចរឿងអង្គសេចក្តី ជាក្រោយ ។

២- ឱ្យខាងអង្គភាពយោធាខេត្តបង្កលក្ខណៈងាយស្រួលដល់ចុងចម្លើយក្នុងការធ្វើស្រែនេះ ។

- សេចក្តីសម្រេចនេះមានអនុភាពអនុវត្តភ្លាមៗ
- បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
- បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៨៣ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ឆ្នាំង សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី២០-០៧-៩៨ ទុកជាមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ប្រគល់ដីស្រែដែលមានទំហំ៦០អា នៅខាងលិចបន្ទាយចាន់ សារិ ឱ្យទៅអង្គភាពតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ឆ្នាំងឈ្មោះ ហៅក្រៅ បន្ទាយ ចាន់ សារិ កាន់កាប់ និងគ្រប់គ្រងដោយចុះក្នុងបញ្ជី សារពើភ័ណ្ឌជាទ្រព្យសម្បត្តិរដ្ឋ តែឱ្យឈ្មោះ បសរ មានសិទ្ធិធ្វើស្រែ នៅលើផ្ទៃដី៦០អា នេះ ក្នុងរយៈពេល ១រដូវប្រមូលកាត់ឆ្នាំ១៩៩៩-២០០០ ។

៣- ប្រគល់ដីបាសាំងទឹក ដែលមានទំហំ៧១ម$^{២}$ និងបាសាំងទឹកឱ្យទៅអង្គភាពតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ឆ្នាំង កាន់កាប់និងគ្រប់គ្រងជាទ្រព្យសម្បត្តិរដ្ឋ ដោយចុះក្នុងបញ្ជីសារពើភ័ណ្ឌ ចាប់គិតពីថ្ងៃ សាលក្រមចូលជាស្ថាពរតទៅ ។

៤- ប្រគល់ដីខាងកើតបាសាំងទឹក ដែលមានទទឹងប្រវែង០,៥០ម និងបណ្តោយ១៣,៣៥ម បន្ថែមពីលើផ្លូវដែលមានពីមុន ដើម្បីរក្សាទុកជាផ្លូវសាធារណៈ ។

៥- ឱ្យឈ្មោះ បសរ រុះរើផ្ទះសង់ពីខាងមុខបាសាំងនេះ ចេញឱ្យអស់ដោយទុករយៈពេល

២ខែ គិតចាប់ពីថ្ងៃ ដែលសាលក្រមចូលជាស្ថាពរ ។

៦- បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ បូករួម៧០០០៛ ។ប្រាក់នេះ បានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុករួច។ បើហួសឧទ្ធរណ៍បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ $\frac{១x១២,០០០,០០០៛}{១០០}$ = ១២០,០០០៛ បន្ថែមទៀត ដែលត្រូវបានដាក់ចូលថវិកាជាតិ៨០ភាគរយ និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ ភាគរយ ។ ពន្ធសមាមាត្រនេះ ត្រូវឱ្យដើមចោទបង់ទុកជាមុនដែរ ទើបឱ្យចុងចម្លើយសងទៅដើមចោទ វិញជាក្រោយ ។

តាមមាត្រា ១ ,២ ,៣ និង មាត្រា៦៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩២ ។ សាលក្រមនេះជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូក្តី។

បើគូក្តីណាមួយមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៦ ចុះថ្ងៃទី៣០ខែកក្កដា ឆ្នាំ១៩៩៩ របស់លោក បសរ ប្តឹងមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ៨៣ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ឆ្នាំង លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៦(ក) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-០៧-៩៩ របស់ឈ្មោះ បសរ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុស និងគតិច្បាប់ ។

២- តម្កល់សាលក្រមលេខ៨៣ ចុះថ្ងៃទី៣០-០៧-៩៩ របស់តុលាការខេត្តកំពង់ឆ្នាំង ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់រួចហើយគឺពន្ធចុះបញ្ជី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជី៤៥០៛ ចំណាយលើកាប្រគល់ដីការកោះ ៥០០០៛ អាជ្ញាធរតុលាការ ៥០០០៛ សរុប ១៣០០០៛ ។

៤- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៧៥ ចុះថ្ងៃទី១៨ ខែកញ្ញាឆ្នាំ២០០០ របស់លោក បសរ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៦៦(ក) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី២៥-០១-២០០១ របស់ឈ្មោះ បសរ អឿ រ៉េត

បានឃើញសារណាតប ចុះថ្ងៃទី១៩-០២-២០០១ របស់ឈ្មោះ ឈុន ឈៃ

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

សាលដីការដ្ឋប្បវេណីលេខ៦៦(ក) ចុះថ្ងៃទី០១ ខែសីហាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ។

**សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។**

បានស្តាប់ចម្លើយរបស់ឈ្មោះ អរជាចុងចម្លើយ និងម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថាខ្លួនបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ព្រោះមានភាពអយុត្តិធម៌ មកលើរូបខ្លួនតាមពិតពួកទាហ៊ានបានរឹបអូសយកដីស្រែគោក្របី នង្គ័ល រនាស់ ថែមទាំងប្រើអំពើហឹង្សាមកលើក្រុមគ្រួសារខ្លួនទៀត ផងចំណែកដីស្រែគឺ ខ្លួនជាអ្នកកាប់គាស់ឆ្ការព្រៃ ដើម្បីយកដីធ្វើស្រែ រីឯដីផ្ទះវិញបានទិញពីឈ្មោះ សោម កេន មានទាំងបាសាំងទឹកតែម្តង ហើយខ្លួនពុំដែលឃើញទាហ៊ានណា ទៅជីកទឹកនៅកន្លែងបាសាំងទឹកនេះទេ ។ បន្ទាយ ចាន់ សារិ នៅប្រហែលជា១០ម៉ែត្រពីផ្ទះខ្លួន តែបន្ទាយនេះប្រើប្រាស់ទឹកអណ្តូងទេ ហើយខ្លួនបានសង់ផ្ទះតាំងពីឆ្នាំ១៩៨៤ នៅក្រោយបាសាំងទឹក ហើយពីមុខបាសាំងទឹកសង់តូបលក់ដូរ ដីនេះមានប្លង់ មានទាំងរដ្ឋអំណាចទទួលស្គាល់ ហើយកម្មសិទ្ធិរបស់ខ្លួនទល់ចិញ្ចើមថ្នល់តែម្តង ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឈុន ឈៃ ជាដើមចោទ និងចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា សុំបដិសេធនូវចម្លើយរបស់ឈ្មោះ អរទាំងអស់ព្រោះដីនេះ ជាដីរបស់យោធាខេត្តកំពង់ឆ្នាំង ហើយបាសាំងទឹកនេះមានតាំងពីសង្គមចាស់មកម្ល៉េះ ។

សូមបញ្ជាក់ថា ដីស្រែដីជុំវិញបាសំងទឹកនិងបាសាំងនេះ មន្ទីរឧស្សាហកម្មខេត្តបានផ្ទេរឱ្យអង្គភាពយោធាចាន់ សារិ តាំងពីថ្ងៃទី២០-០៥-៨៣ មក ។

នៅឆ្នាំ១៩៩៨ ឈ្មោះ បសរ បានរុះរើផ្ទះមកសង់ខាងមុខ ដែលធ្វើឱ្យប៉ះពាល់ដល់ការ យកទឹករបស់យោធា រីឯដីស្រែ អណ្តូងទឹក បាសាំងទឹក ក៏ជាសម្បត្តិរបស់រដ្ឋដែរ ព្រោះយោធាជាអ្នកកាន់កាប់ ។ នៅពេល បសរ ធ្វើតូបប៉ះកង់នៅពីមុខបាសាំងទឹក ពេលនោះគឺយោធាអាធ្យាស្រ័យឱ្យដោយសារឃើញថាមានជីវភាពក្រលំបាក ក៏អនុញ្ញាតិឱ្យធ្វើ ដើម្បីជីវភាព ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ........ ការពារក្តីឱ្យឈ្មោះ អរបាន បញ្ជាក់ថាៈ រឿងនេះ មាន២ ករណីមួយគឺ ដីលំនៅដ្ឋាន និងករណីមួយទៀតគឺ ដីស្រែ

នៅឆ្នាំ១៩៨២ ឈ្មោះបសរ បានមករស់នៅលើដីនេះ គឺនៅទល់មុខបន្ទាយ ចាន់ សារិ តែម្តង ។

នៅឆ្នាំ១៩៨៩ បានធ្វើពាក្យសុំកាន់កាប់ដីធ្លី លំនៅដ្ឋានដែលមានទំហំ៤៥៦ម$^{២}$ ដោយមានការឯកភាពមូលដ្ឋាន និងមានបង្កាន់ដៃទៀតផង ។

នៅឆ្នាំ១៩៨៧ ដីស្រែកូនក្តីរបស់ខ្លួនបានគាស់រាន ដើម្បីធ្វើស្រែ ដោយមានរដ្ឋអំណាចមូលដ្ឋាន

ទទួលស្គាល់ ដែលចេញដោយកសិកម្មឃុំ ។ កូនក្តីរបស់ខ្ញុំបាទបានមករស់នៅលើដីនេះ ពុំដែលមានទំនាស់ទេ គឺបានកាន់កាប់ដីនេះ អស់រយៈពេលយ៉ាងយូរ ដែលជាហេតុធ្វើឱ្យកូនក្តីរបស់ខ្ញុំបាទមានសិទ្ធិភោគៈ លើដីនេះគ្រប់គ្រាន់ហើយ។

**អំពីអង្គច្បាប់ :**

តាំងពីឆ្នាំ១៩៨២ រហូតដល់១៩៨៨ មានរយៈពេល១៦ឆ្នាំ ដូចនេះតាមច្បាប់ភូមិបាលឈ្មោះ បសរ មានសិទ្ធិពេញលេញដើម្បីរស់នៅតាមផ្លូវច្បាប់ ។

សូមបដិសេធ នូវសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទាំងស្រុង និងសូមក្រុមប្រឹក្សាជំនុំជំរះសម្រេចឱ្យ កូនក្តីរបស់ខ្ញុំបាទមានយុត្តិធម៌ផង ។

បានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវី លោក ........ ការពារក្តីឱ្យឈ្មោះ ឈួន ឈៃ បាន បញ្ជាក់ថា រឿងនេះ មាន២ករណីគឺ ដីផ្ទះ និង ដីស្រែ សូមបញ្ជាក់ថា តុលាការខេត្តកំពង់ឆ្នាំង បានអង្កេតពេញលេញ ហើយ មុននឹងលើកយករឿងនេះមកជំនុំជំរះ ។

ដីទំនាស់នេះ ជាដីរបស់បន្ទាយ ចាន់ សារិ ដែលមន្ទីរឧស្សាហកម្មខេត្តកំពង់ឆ្នាំង បានប្រគល់ឱ្យនៅឆ្នាំ១៩៨៣ ហើយបាសាំងទឹកនេះ អង្គភាពយោធា ប្រើប្រាស់ក្នុងការយកទឹកទៅផ្គត់ផ្គង់យោធានៅក្នុងបន្ទាយ ដូចនេះបញ្ជាក់ច្បាស់ថា ដីទំនាស់នេះ ជាកម្មសិទ្ធិរបស់រដ្ឋពិតប្រាកដមែន ។ ពេលដែលឈ្មោះ បសរ មកធ្វើផ្ទះក្រោយបាសាំងទឹក និងធ្វើតូបប៉ះកង់ នៅពីមុខបាសាំងទឹកនោះ ដោយអង្គភាពយោធាយល់ថា ជាពលរដ្ឋក្រីក្ររកស៊ី ដើម្បីជីវភាពបន្តិចបន្តួច ក៏អនុញ្ញាតិជាបណ្តោះអាសន្នទៅ លុះដល់ពេលស្រុកទេសផ្លាស់ប្តូររបបនយោបាយស្រាប់តែ ឈ្មោះ បសរ មានការលោភលន់ចង់យកដីទំនាស់នេះ ជាកម្មសិទ្ធិរបស់ខ្លួនតែម្តង ។

ដីស្រែដែលមានទំនាស់នេះ បានចុះបញ្ជីសារពើភ័ណនៅឆ្នាំ១៩៩០ ដែលជាកម្មសិទ្ធិរបស់រដ្ឋ

**អំពីអង្គច្បាប់**

ចំពោះបញ្ហាដីទំនាស់រវាងលោក បសរ និង អង្គភាពយោធា ខេត្តកំពង់ឆ្នាំង បញ្ជាក់ឱ្យ ឃើញថាលោក បសរ មិនបានបំពេញតាមលក្ខខ័ណ្ឌរបស់ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា៥៨ និង ច្បាប់ភូមិបាល ដែលខ្លួន ជាពលរដ្ឋត្រូវតែបំពេញកាតព្វកិច្ចនេះ ។

សំណូមពរ សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីនៃគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៧៥ ចុះថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ២០០០ របស់លោកបសរ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី ។

-យល់ឃើញថាដីស្រែ ដីជុំវិញបាសាំងទឹកព្រមទាំងបាសាំងទឹកនេះ ត្រូវបានមន្ទីរឧស្សាហកម្មខេត្តកំពង់ឆ្នាំងផ្ទេរមកឱ្យអង្គភាពយោធាបន្ទាយចាន់ សារិ តាមកំណត់ហេតុ ចុះថ្ងៃទី២០-០៥-៨៣ ដូច្នេះអង្គភាពនេះ មានសិទ្ធិគ្រប់គ្រាន់លើដីទំនាស់ និងបាសាំងទឹកនេះ ។

-យល់ឃើញថា បាសាំងទឹកនេះ ត្រូវបានអង្គភាពយោធាបន្ទាយចាន់ សារិ ជួសជុល និងប្រើប្រាស់ជាប់ជាប្រចាំ តាំងពីឆ្នាំ១៩៨៤ រហូតមកហើយ ផ្ទៃដីជុំវិញបាសាំងទឹកនេះ ជាទីតាំងសេវភាពសម្រាប់ចេញចូលប្រើប្រាស់បាសាំងទឹក ដូច្នេះលោក បសរ ពុំមានសិទ្ធិប្រើប្រាស់ដីនេះជាកម្មសិទ្ធិផ្ទាល់ខ្លួនបានឡើយ ។

-យល់ឃើញថា ដីស្រែទំនាស់នេះ ស្ថិតនៅក្នុងបរិវេណរបងបន្ទាយ ចាន់ សារិ និងស្ថិតនៅក្នុងបរមាណផ្ទៃដីដែល មន្ទីរឧស្សាហកម្មខេត្តបានប្រគល់ឱ្យអង្គភាពយោធា តាំងពីឆ្នាំ១៩៨៣ មកម្លេះ ហើយលោកបសរ ទើបតែធ្វើស្រែនៅឆ្នាំ១៩៨៨ មកទេហើយគ្មានភស្តុតាងណាបញ្ជាក់ថា រដ្ឋអំណាចឬ អង្គភាពយោធាបានប្រគល់ឱ្យលោកឡើយ ដូច្នេះ លោក ពុំអាចឡើងជាម្ចាស់នៃដីទំនាស់បានទេ ពីព្រោះជាការរំលោភទៅលើមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

-យល់ឃើញថា ខ្លឹមសារសារណា ចុះថ្ងៃទី២៥-០១-២០០១ របស់លោក បសរ ដែលបានដាក់ជូនមកតុលាការកំពូល តុលាការថ្នាក់ក្រោម បានពិចារណារួចត្រឹមត្រូវអស់ហើយ ។

-យល់ឃើញថា ការដែលមេធាវី ចុងចម្លើយបានលើកឡើងនាពេលសវនាការនេះថា កូនក្តីរបស់លោក បានកាន់កាប់ដីស្រែទំនាស់នេះ អស់ពេល១៦ឆ្នាំ ហើយធ្វើឱ្យកូនក្តីលោកមានសិទ្ធិលើដីទំនាស់នោះជាការ ភ័ន្តច្រឡំហើយ ពីព្រោះថាដីនេះមិនមែនទំនេរទេ គឺជាដីដែលមន្ទីរឧស្សាហកម្មខេត្តកំពង់ឆ្នាំងបានប្រគល់ឱ្យ អង្គភាពយោធា តាំងពីឆ្នាំ១៩៨៣មកម្លេះ ។ ដូច្នេះការកាន់កាប់របស់កូនក្តីលោក គឺរំលោភទៅលើមាត្រា៧៤ នៃច្បាប់ភូមិបាល ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៦៦(ក) ចុះថ្ងៃទី០១-០៨-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

និច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៣៧៥ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ របស់លោក បសរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៦៦(ក) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោក ឈុន ឈៃ បានបង់ជួសរួចហើយគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវ ឱ្យលោក បសរ សងប្រាក់១៩០០០រៀល នេះ ទៅឱ្យលោក ឈុន ឈៃ វិញ ។

បង្គាប់ឱ្យលោក បសរ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តកំពង់ឆ្នាំង ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ ។